## ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ : ០៥៤/១៩ ក.ប/ស.ណ.ន.ខ.ល

# សេចក្តីណែនាំ

## ស្តីពី

## ការអនុវត្តប្រកាសលេខ៤៤២ និងលេខ៤៤៣ ក.ប/ប្រ.ក.ខល ចំពោះបុគ្គលិក នៃស្ថានតំណាងបរទេស ភ្នាក់ងារនៃអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានាប្រចាំនៅកម្ពុជា

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនប្រធាន និងបុគ្គលិកនៃស្ថានតំណាងបរទេស ភ្នាក់ងារនៃអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានាប្រចាំនៅកម្ពុជា ជ្រាបថា យោងតាមអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីទំនាក់ទំនងការទូតនិងកុងស៊ុល បុគ្គលិកដែលបម្រើការងារនៅតាមស្ថានតំណាងបរទេស ភ្នាក់ងារនៃអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានាប្រចាំនៅកម្ពុជា ត្រូវបានលើកលែងចំពោះការអនុវត្តប្រកាសលេខ៤៤២ ក.ប/ប្រ.ក.ខល ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការបើកប្រាក់ឈ្នួលជូនកម្មករនិយោជិត និងប្រកាសលេខ៤៤៣ ក.ប/ប្រ.ក.ខល ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការទូទាត់ប្រាក់បំណាច់អតីតភាពការងារ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានក្តីសង្ឃឹមយ៉ាងមុតមាំថា ប្រធាន និងបុគ្គលិកនៃស្ថានតំណាងបរទេស ភ្នាក់ងារនៃអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានាប្រចាំនៅកម្ពុជាទាំងអស់នឹងអនុវត្តតាមខ្លឹមសារសេចក្តីណែនាំនេះបានត្រឹមត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃ សុក្រ ១កើត ខែចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមេសា ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ

  "ដើម្បីជូនជ្រាប"
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត
- សហជីព និងសមាគមនិយោជកគ្រប់លំដាប់ថ្នាក់

  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ